U.S. Department of Housing and Urban Development
Office of Housing    Office of Multifamily Housing Programs

# ក្រដាសការណ៍ពិត

## សំរាប់អ្នកមូលដ្ឋានដែល HUD ជួយ

## ផ្នែក 236

# “ថ្លៃជួលរបស់អ្នក ត្រូវបាន អនុម័តដោយដូចម្តេច”

**ការិយាល័យទីលំនៅ**

**ខែមិថុនា  2007**

*ក្រដាសការណ៍ពិតនេះ គឺជាសេចក្តីណែនាំទូទៅ ដើម្បីជំរាបម្ចាស់ផ្ទះ/ភ្នាក់ងារចាត់ចែងការ (Management Agents - OA) និងអ្នកមូលដ្ឋាន ដែល HUD ជួយ (HUD-assisted residents) អំពីការទទួលខុសត្រូវ និងសិទ្ធិ ស្តីពីការបើកសំដែង និងការបញ្ជាក់ប្រាក់ចំណូល ។*

## ហេតុអ្វីបានជាការអនុម័តប្រាក់ចំណូល និងថ្លៃជួល ដោយត្រឹមត្រូវ មានសារៈសំខាន់អ្វីម្ល៉េះ

ការសិក្សារបស់ ក្រសួងទីលំនៅនិងវឌ្ឍនកម្មទីក្រុង (Department of Housing and Urban Development) បង្ហាញថាអ្នកមូលដ្ឋានជាច្រើន បង់ថ្លៃជួលមិនត្រឹមត្រូវទេ ។  បុព្វហេតុចំបងនៃបញ្ហានេះគឺ :

- ការរាយការណ៍ប្រាក់ចំណូលមិនពិតប្រាកដ ដោយគ្រួសារអ្នកមូលដ្ឋាន, និង
- OA មិនយល់ព្រមការផាត់ចេញ និងការកាត់បន្ថយ ចំពោះគ្រួសារអ្នកមូលដ្ឋានដែលមានសិទ្ធិទទួល ។

OA និងអ្នកមូលដ្ឋានទាំងអស់ សុទ្ធតែមានការទទួលខុសត្រូវ ដោយធ្វើឲ្យប្រាកដថាបានបង់ថ្លៃជួលត្រឹមត្រូវ ។

### ការទទួលខុសត្រូវរបស់ OA :

- ទទួលព័ត៌មានប្រាក់ចំណូលត្រឹមត្រូវ
- បញ្ជាក់ប្រាក់ចំណូលរបស់អ្នកមូលដ្ឋាន
- ធ្វើឲ្យប្រាកដថាអ្នកមូលដ្ឋាន ទទួលការផាត់ចេញ និងការកាត់បន្ថយ ដែលគេមានសិទ្ធិទទួល
- គិតគូរថ្លៃជួលរបស់អ្នកជួលផ្ទះ ដោយត្រឹមត្រូវ
- ផ្តល់ឲ្យអ្នកមូលដ្ឋាន នូវសំណៅនៃកិច្ចព្រមព្រៀង និងការអនុម័តប្រាក់ចំណូល និងថ្លៃជួល
- គិតគូរថ្លៃជួលសាជាថ្មី នៅពេលមានការផ្លាស់ប្តូរសមាសភាពគ្រួសារ ដែលបានរាយការណ៍
- គិតគូរថ្លៃជួលសាជាថ្មី នៅពេលប្រាក់ចំណូលរបស់អ្នកមូលដ្ឋានចុះថយ
- គិតគូរថ្លៃជួលសាជាថ្មី នៅពេលប្រាក់ចំណូលរបស់អ្នកមូលដ្ឋានកើនឡើង ដោយ $200 ឬច្រើនជាង ក្នុងមួយខែ
- ផ្តល់ព័ត៌មានស្តីពីក្រឹត្យក្រមរបស់ OA ទៅតាមសំណូមពរ
- ជូនដំណឹងអ្នកមូលដ្ឋានអំពីការផ្លាស់ប្តូរ ក្នុងសេចក្តីដំរូវ ឬការអនុវត្តន៍ សំរាប់របាយការណ៍ប្រាក់ចំណូល ឬការអនុម័តថ្លៃជួល

### ការទទួលខុសត្រូវរបស់អ្នកមូលដ្ឋាន :

- ផ្តល់ព័ត៌មានសមាសភាពគ្រួសារដោយត្រឹមត្រូវ
- រាយការណ៍ប្រាក់ចំណូលទាំងអស់
- រក្សាទុកសំណៅនៃក្រដាសស្នាម ក្រដាសបំពេញ និងបង្កាន់ដៃ ដែលជាឯកសារនៃប្រាក់ចំណូល និងការចំណាយ
- រាយការណ៍ពីការផ្លាស់ប្តូរសមាសភាពគ្រួសារ និងប្រាក់ចំណូល ដែលកើតឡើងក្នុងរវាងពេលការបញ្ជាក់សាថ្មីជាប្រចាំឆ្នាំ
- ចុះហត្ថលេខាក្រដាសបំពេញការយល់ព្រម សំរាប់ការបញ្ជាក់ប្រាក់ចំណូល
- ធ្វើតាមសេចក្តីដំរូវនៃកិច្ចសន្យាជួល និងច្បាប់ទីលំនៅ

## ការអនុម័តប្រាក់ចំណូល

ប្រាក់ចំណូលរួមរបស់គ្រួសារដែលសង្ឃឹមមាន មិនអនុម័តត្រឹមតែសិទ្ធិទទួលប៉ុណ្ណោះទេ ប៉ុន្តែក៏អនុម័តថ្លៃជួលដែលគ្រួសារនឹងត្រូវបង់ដែរ ។ ប្រាក់ចំណូលសង្ឃឹមមាន យោងទៅលើការផាត់ចេញ និងការកាត់បន្ថយ ដែលគ្រួសារនឹងទទួលក្នុងពេលដប់ពីរ (12) ខែបន្ទាប់ទៀត ត្រូវបាន ប្រើដើម្បីអនុម័តថ្លៃជួលរបស់គ្រួសារ ។

**តើប្រាក់ចំណូលប្រចាំឆ្នាំ ជាអ្វី?**

ប្រាក់ចំណូលរួម – ការផាត់ប្រាក់ចំណូល = ប្រាក់ចំណូលប្រចាំឆ្នាំ

**តើប្រាក់ចំណូលបានសំរួល ជាអ្វី?**

ប្រាក់ចំណូលប្រចាំឆ្នាំ – ការកាត់បន្ថយ = ប្រាក់ចំណូលបានសំរួល

## ការអនុម័តថ្លៃជួលរបស់អ្នកជួលផ្ទះ

រូបមន្តថ្លៃជួលផ្ទះ ផ្នែក 236 :
គេហដ្ឋានផ្នែក 236 ទាំងអស់ សុទ្ធតែមានថ្លៃជួលជាអប្បរិមា (ថ្លៃជួលជាធម្មតា) និងថ្លៃជួលជាអតិបរិមា (ថ្លៃជួលតាមដំឡៃទីផ្សារ) ។

**ផ្នែក 236 ដោយគ្មានការអនុញ្ញាតថ្លៃទឹកភ្លើង; ខ្ពស់ជាងនៃ :**

- 30% នៃប្រាក់ចំណូលប្រចាំខែបានសំរួលរបស់គ្រួសារ
- ថ្លៃជួលជាធម្មតា
- ប៉ុន្តែមិនលើសពីថ្លៃជួលតាមដំឡៃទីផ្សារ

**ផ្នែក 236 ដោយមានការអនុញ្ញាតថ្លៃទឹកភ្លើង; ខ្ពស់ជាងនៃ :**

- 30% នៃប្រាក់ចំណូលប្រចាំខែបានសំរួលរបស់គ្រួសារ ដកការអនុញ្ញាតថ្លៃទឹកភ្លើង
- 25% នៃប្រាក់ចំណូលប្រចាំខែបានសំរួលរបស់គ្រួសារ
- ថ្លៃជួលជាធម្មតា
- ប៉ុន្តែមិនលើសពីថ្លៃជួលតាមដំឡៃទីផ្សារ

**ការអនុញ្ញាតថ្លៃទឹកភ្លើង** ត្រូវបានយល់ព្រមដោយ HUD នៅពេលដំឡៃ ទាំងអស់ ឬផ្នែកខ្លះនៃថ្លៃទឹកភ្លើង (លើកលែងទូរស័ព្ទ) មិនបញ្ចូលក្នុង ថ្លៃជួលលំនៅ ហើយការបង់ប្រាក់សំរាប់ថ្លៃទឹកភ្លើង គឺជាការទទួលខុស ត្រូវនៃគ្រួសារដែលរស់នៅក្នុងលំនៅ ។ ការអនុញ្ញាតថ្លៃទឹកភ្លើង គឺមិន មែនមានន័យថាត្រូវបង់ថ្លៃទឹកភ្លើងពិតប្រាកដទាំងអស់ទេ ប៉ុន្តែជាការ អនុញ្ញាតដែលបានផ្តល់ទៅឲ្យគ្រួសារ ដើម្បីជួយគេក្នុងការចំណាយ លើទឹកភ្លើងរបស់គេ ។

## ប្រាក់ចំណូល និងទ្រព្យធន

អ្នកមូលដ្ឋានដែល HUD ជួយ គឺបានដំរូវឲ្យរាយការណ៍ប្រាក់ចំណូល **ទាំងអស់** ចេញពីប្រភពទាំងអស់ ទៅឲ្យម្ចាស់ផ្ទះ ឬភ្នាក់ងារ (OA) ។ ការផាត់ចេញចំពោះប្រាក់ចំណូល និងការកាត់បន្ថយ គឺជាផ្នែកនៃវិធីថ្លៃជួលរបស់អ្នកជួលផ្ទះ ។

នៅពេលអនុម័តចំនួននៃប្រាក់ចំណូល ចេញពីទ្រព្យធន ដើម្បីបញ្ចូលក្នុងប្រាក់ចំណូលប្រចាំឆ្នាំ ប្រាក់ចំណូលពិតប្រាកដដែលបានយកចេញពីទ្រព្យធនត្រូវបានបញ្ចូល លើកលែងតែនៅពេលដំឡៃប្រាក់សុទ្ធនៃទ្រព្យធនទាំងអស់លើសពី $5,000 ទើបចំនួនដែលបញ្ចូលក្នុងប្រាក់ចំណូលប្រចាំឆ្នាំ គឺខ្ពស់ជាង 2% នៃទ្រព្យធនសរុបទាំងអស់ ឬប្រាក់ចំណូលពិតប្រាកដបានយកចេញពីទ្រព្យធន ។

ប្រាក់ចំណូលប្រចាំឆ្នាំបញ្ចូល :

- ចំនួនពេញ (មុនការកាត់បន្ថយពន្ធដារ) នៃប្រាក់ឈ្នួល និងប្រាក់ខែ, ប្រាក់ធ្វើការលើសម៉ោង, កំរៃជើងសារ, ឈ្នួល, ប្រាក់ទឹកតែ និងប្រាក់បន្ថែម និងការសងថ្លៃផ្សេងៗទៀត សំរាប់សេវាផ្ទាល់ខ្លួន
- ប្រាក់ចំណូលទូទាត់រួច ចេញពីការប្រកបមុខរបរ ឬវិជ្ជាជីវៈ
- ការប្រាក់, ប្រាក់ចំណែកចំណេញទុន និងប្រាក់ចំណូលទូទាត់រួច ផ្សេងទៀត នៃប្រភេទណាមួយចេញពីអចលនាទ្រព្យ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួន (មើល ទ្រព្យធនបញ្ចូល/ទ្រព្យធនមិនបញ្ចូល នៅខាងក្រោម)
- ចំនួនពេញនៃចំនួនបានទទួលម្តងម្កាល ចេញពីសូស្យ៉ាល់សឺគ្យួរិទី, ប្រាក់បើកឲ្យប្រចាំឆ្នាំ, ប្រាក់ច្បាប់ធានារ៉ាប់រង, ថវិការ៉ុត្រៃត, ប្រាក់និវត្តន៍, ប្រាក់ពិការ ឬប្រាក់អត្ថប្រយោជន៍មរណភាព និងប្រភេទស្រដៀងគ្នាផ្សេងទៀត នៃបង្កាន់ដៃម្តងម្កាល រួមមានចំនួនប្រាក់បើកឲ្យសរុប ឬចំនួនជាប្រចាំខែបំរុងនឹងមាន សំរាប់ពន្យារពេល ចាប់ផ្តើមនៃចំនួនម្តងម្កាល **លើកលែងតែការបើកប្រាក់ម្តងម្កាល ដោយលើកពេល នៃប្រាក់ចំណូលសូស្យ៉ាល់សឺគ្យួរិទីបន្ថែម និងអត្ថប្រយោជន៍សូស្យ៉ាល់សឺគ្យួរិទី, សូមមើល ការផាត់ចេញពីប្រាក់ចំណូលប្រចាំឆ្នាំ នៅខាងក្រោម) **
- ការបើកប្រាក់ជំនួសនៃប្រាក់រកបាន, ដូចជាប្រាក់អត់ការងារធ្វើ និងប្រាក់សំណងភាពពិការ, ប្រាក់សំណងកម្មករព្រោះមានគ្រោះថ្នាក់នៅការដ្ឋាន និងប្រាក់បំណាច់ **(លើកលែងតែប្រាក់បើកឲ្យសរុប បន្ថែមទៅលើទ្រព្យធនគ្រួសារ, សូមមើលការផាត់ចេញពីប្រាក់ចំណូលប្រចាំឆ្នាំ នៅខាងក្រោម) **
- ជំនួយវែលហ្វែរ
- ប្រាក់បើកម្តងម្កាល និងប្រាក់អនុញ្ញាតដែលអាចអនុម័តបាន ដូចជាប្រាក់ឧបត្ថម្ភប្រពន្ធប្តី និងប្រាក់ឧបត្ថម្ភកូន និងការបរិច្ចាគទៀងទាត់ ឬអំណោយបានទទួលពីអង្គការ ឬចេញពីមនុស្សដែលមិនរស់នៅក្នុងលំនៅ
- ប្រាក់បើកទៀងទាត់ទាំងអស់, ប្រាក់បើកពិសេស និងប្រាក់អនុញ្ញាត នៃសមាជិកកងកំឡាំងប្រដាប់អាវុធ (លើកលែងតែប្រាក់បើកពិសេស សំរាប់ការប្រយុទ្ធសត្រូវ)

- **សំរាប់តែកម្មវិធីផ្នែក 8 ប៉ុណ្ណោះ ចំនួនជំនួយហិរញ្ញវត្ថុអ្វីមួយដែលលើសចំនួនដែលបានទទួល សំរាប់ថ្លៃសិក្សាដែលបុគ្គលម្នាក់ទទួលក្រោមក្រឹត្យការអប់រំខ្ពង់ខ្ពស់ជាង (Higher Education Act) នៃឆ្នាំ 1965 ត្រូវបានចាត់ទុកជាប្រាក់ចំណូលរបស់បុគ្គលនោះ លើកលែងតែជំនួយហិរញ្ញវត្ថុដែលមិនបានចាត់ទុកជាប្រាក់ចំណូល សំរាប់មនុស្សអាយុលើសពី 23 ឆ្នាំ ដែលមានកូននៅក្នុងបន្ទុក ឬបើសិស្សម្នាក់កំពុងតែរស់នៅជាមួយនឹងមាតា-បិតារបស់គាត់ ដែលកំពុងតែទទួលជំនួយផ្នែក 8 ។ សំរាប់គោល បំណងនៃវគ្គនេះ ពាក្យ "ជំនួយហិរញ្ញវត្ថុ" មិនរាប់បញ្ចូលប្រាក់ខ្ចីគេ សំរាប់គោលបំណងនៃការអនុម័តប្រាក់ចំណូលឡើយ**

ទ្រព្យធនបញ្ចូល ៖

- ស្តុក, ប្រាក់ដំកល់ទុក, រតនាគារប័ត្រ, សំបុត្រការដាក់ប្រាក់ទុក, កុងប្រាក់ផ្សារយកទុន
- ប្រាក់រ៉ឺត្រែតរបស់បុគ្គល និងកុង Keogh
- ប្រាក់រ៉ឺត្រែត និងថវិការនិវត្តន៍
- ប្រាក់សុទ្ធបានទុកក្នុងកុងសន្សំប្រាក់ទុក និងកុងសរសេរសែកបាន, ប្រអប់ទុកដាក់ឲ្យគង់វង្ស, ផ្ទះ, ជាដើម
- ដំឡៃប្រាក់សុទ្ធ នៃច្បាប់ធានារ៉ាប់រងជីវិតទាំងមូល ដែលមានសំរាប់បុគ្គលមុនពេលស្លាប់
- ប្រាក់សមចំណែកដំឡៃទ្រព្យ ក្នុងការជួលផ្ទះ និងការវិនិយោគទុនផ្សេងទៀត
- ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលបានទុកជាវិនិយោគទុន
- បង្កាន់ដៃប្រាក់បើកសរុប ឬបង្កាន់ដៃប្រាក់បើកតែម្តង
- ប្រាក់បុលទិញផ្ទះ ឬរាគហ៊ុន ដែលបានទុកដោយអ្នកដាក់ពាក្យសុំ
- ទ្រព្យធនដែលបានវេរបង់ ដែលថោកជាងដំឡៃសមរម្យនៃទីផ្សារ

ទ្រព្យធនមិនបញ្ចូល ៖

- ទ្រព្យសម្បត្តិផ្ទាល់ខ្លួនជាចាំបាច់ (សំលៀកបំពាក់, តុទូកៅអី, ឡាន, ចិញ្ចៀនរៀបការ, រថយន្តពិសេសដែលមានប្រដាប់ប្រដាសំរាប់មនុស្សពិការ)
- ការប្រាក់ក្នុងកូនធនាគារដីឥណ្ឌាន
- លក្ខខ័ណ្ឌច្បាប់សន្យាធានារ៉ាប់រងជីវិត
- ប្រាក់សមចំណែកដំឡៃទ្រព្យ ក្នុងក្រុមសហករដែលគ្រួសាររស់នៅ
- ទ្រព្យធនដែលជាផ្នែកនៃសកម្មជំនួញ
- ទ្រព្យធនដែលមានម្ចាស់មិនស័ក្តិសិទ្ធិ ដោយអ្នកដាក់ពាក្យសុំ ឬបានទុកក្នុងឈ្មោះរបស់បុគ្គល ប៉ុន្តែ ៖
  - ទ្រព្យធន និងប្រាក់ចំណូលអ្វីមួយ ដែលគេបានថែម ទៅលើផលប្រយោជន៍នៃមនុស្សផ្សេងទៀត ដែលមិនមែនជាសមាជិកនៃក្រុមគ្រួសារ, និង
  - មនុស្សផ្សេងនោះទទួលខុសត្រូវសំរាប់ពន្ធដារប្រាក់ចំណូលដែលបានមកពីប្រាក់ចំណូល បានបង្កើតឡើងដោយទ្រព្យធន
- ទ្រព្យធនដែលអ្នកដាក់ពាក្យសុំមិនអាចយកបាន និងមិនផ្តល់ជាប្រាក់ចំណូល សំរាប់អ្នកដាក់ពាក្យសុំ (ឧទាហរណ៍ ៖ ប្រពន្ធដែលត្រូវបានគេវាយដំ ជាម្ចាស់ផ្ទះជាមួយនឹងប្តីរបស់នាង ។ អាស្រ័យទៅលើស្ថានការណ៍ហឹង្សាក្នុងគ្រួសារ នាងគ្មានទទួលប្រាក់ចំណូលចេញពីទ្រព្យធនទេ ហើយក៏មិនអាចដូរទ្រព្យធនទៅជាប្រាក់សុទ្ធបានឡើយ)
- ទ្រព្យធនដែលបានវេរបង់ ដែលថោកជាងដំឡៃសមរម្យនៃទីផ្សារ ជាលទ្ធផលនៃ ៖
  - ធនាគាររឹបអូសផ្ទះមុនដាច់ប្រាក់បុល
  - ធនក្ស័យ
  - កិច្ចព្រមព្រៀងលែងលះគ្នា ឬព្រាត់គ្នា បើអ្នកដាក់ពាក្យសុំ ឬអ្នកមូលដ្ឋានទទួលការពិចារណាសំខាន់ មិនចាំបាច់ជាប្រាក់កាស។

ការផាត់ចេញពីប្រាក់ចំណូលប្រចាំឆ្នាំ ៖

- ប្រាក់ចំណូលចេញពីការងារនៃក្មេងៗ (រួមទាំងកូនចិញ្ចឹម) ក្រោមអាយុ 18 ឆ្នាំ
- ការបង់ប្រាក់ បានទទួលសំរាប់ថែទាំនៃក្មេងៗជាកូនចិញ្ចឹម ឬចិញ្ចឹមមនុស្សពេញវ័យជាអ្នកជំងឺ (តាមធម្មតាជាមនុស្សពិការ មិនជាប់សាច់ញាតិនៃគ្រួសារអ្នកជួលផ្ទះ ដែលពុំអាចរស់នៅម្នាក់ឯងបាន
- ប្រាក់បើកសរុប បន្ថែមទៅលើទ្រព្យធនរបស់គ្រួសារ ដូចជាកេរ្តិ៍អាករ, ប្រាក់ធានារ៉ាប់រង (រួមទាំងប្រាក់ក្រោមការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ និងសំណងកម្មករព្រោះគ្រោះថ្នាក់នៅការដ្ឋាន), ប្រាក់ចំណេញមូលធន និងប្រាក់សំរុះសំរួលគ្នា សំរាប់ផ្ទាល់ខ្លួន ឬការខាតបង់ទ្រព្យសម្បត្តិ
- ចំនួនបានទទួលដោយគ្រួសារ សំរាប់ការអ្វីជាក់លាក់ ឬជាការសងឲ្យវិញនៃដំឡៃការចំណាយថ្លៃពេទ្យ សំរាប់សមាជិកគ្រួសារណាម្នាក់
- ប្រាក់ចំណូលនៃជំនួយរស់នៅ-ជាមួយគេ
- **អនុវត្តចំពោះការផាត់ចេញនៃប្រាក់ចំណូល សំរាប់កម្មវិធីផ្នែក 8 សំរាប់សិស្សដែលបានចុះឈ្មោះរៀនក្នុងគ្រឹស្ថាននៃការអប់រំខ្ពង់

ខ្ពស់ជាង ក្រោមប្រាក់ចំណូលប្រចាំឆ្នាំបញ្ចូលនៅខាងលើ **ចំនួនពេញនៃជំនួយហិរញ្ញវត្ថុសិស្ស ទោះជាបានបង់ទៅឲ្យសិស្សផ្ទាល់ ឬបង់ទៅឲ្យគ្រឹស្ថានអប់រំ

- ប្រាក់បើកពិសេស ទៅឲ្យសមាជិកគ្រួសារដែលបំរើកងកំឡាំងប្រដាប់អាវុធ ដែលប្រឈមនឹងសត្រូវ
- ចំនួនបានទទួលក្រោមកម្មវិធីការហ្វឹកហ្វឺន ដែល HUD បានផ្តល់ថវិកា
- ចំនួនបានទទួលដោយមនុស្សពិការ ដែលចាត់ទុកជាអសារឥតការ សំរាប់ពេលវេលាមានកំរិត សំរាប់គោលបំណងនៃសិទ្ធិទទួលប្រាក់ចំណូលសូស្យ៉ាល់សឺគួរិទីបន្ថែម និងអត្ថប្រយោជន៍ ពីព្រោះវាបានទុកជាដោយឡែក សំរាប់ប្រើក្រោមគំរោងដើម្បីឲ្យបានធូនអាត្មា (Plan to Attain Self-Sufficiency - PASS)
- ចំនួនបានទទួលដោយអ្នកចូលរួម ក្នុងកម្មវិធីសាធារណៈបានជួយផ្សេងទៀត សំរាប់ការអ្វីជាក់លាក់ ឬក្នុងការសងប្រាក់ឲ្យវិញ នៃការចំណាយ-ពី-ហោប៉ៅ ដែលជំពាក់ (ប្រដាប់ប្រដាពិសេស, សំលៀកបំពាក់, យានជំនិះ, ថ្លៃថែទាំក្មេង ជាដើម) និងដែលបានធ្វើតែដើម្បីអនុញ្ញាតឲ្យមានការចូលរួមក្នុងកម្មវិធីជាក់លាក់មួយ
- ប្រាក់សគុណសេវាអ្នកមូលដ្ឋាន (មិនលើសពី $200 ក្នុងមួយខែ)
- ប្រាក់រកបានបន្ថែម និងអត្ថប្រយោជន៍ បណ្តលទៅលើសមាជិកគ្រួសារណាម្នាក់ ចេញអំពីការចូលរួមក្នុងកម្មវិធីរដ្ឋដែលមានគុណសម្បត្តិ ឬកម្មវិធីហ្វឹកហ្វឺនការងារក្នុងតំបន់ និងការហ្វឹកហ្វឺនសមាជិកគ្រួសារ ជាបុគ្គលិកចាត់ចែងអ្នកមូលដ្ឋាន
- ប្រាក់ចំណូលបណ្តោះអាសន្ន, មិនមានជារឿយៗ ឬយូរៗម្តង (រួមទាំងអំណោយ)
- ការបង់ប្រាក់សំណង បានបង់ឲ្យដោយរដ្ឋាភិបាលបរទេស អនុលោមចំពោះការប្តឹងទាមទារ បានប្តឹងតាមច្បាប់នៃរដ្ឋាភិបាលនោះ ដោយមនុស្សដែលត្រូវបានកាត់ទោសក្នុងសម័យណាស៊ី
- ប្រាក់រកបានលើសពី $480 សំរាប់សិស្សរៀនពេញពេលនិមួយៗ អាយុ 18 ឆ្នាំ ឬចាស់ជាង (មិនរាប់មេគ្រួសារ អនុមេគ្រួសារ ឬប្រពន្ធប្តី)
- ការបង់ប្រាក់ជំនួយការចិញ្ចឹមកូនគេ ដែលលើសពី $480 សំរាប់កូនចិញ្ចឹមម្នាក់
- ការបង់ប្រាក់ដោយលើកពេលម្តងម្កាល នៃប្រាក់ចំណូលសូស្យ៉ាល់សឺគួរិទីបន្ថែម និងអត្ថប្រយោជន៍សូស្យ៉ាល់សឺគួរិទី ដែលបានទទួលជាសរុបចំនួន ឬចំនួនជាប្រចាំខែនៅអនាគត
- ចំនួនបានទទួលដោយគ្រួសារ ជាទំរង់នៃការបានប្រាក់មកវិញ ឬប្រាក់បង្វិលឲ្យមកវិញ នៅក្រោមច្បាប់រដ្ឋ ឬរដ្ឋាភិបាលតាមតំបន់ សំរាប់ពន្ធដារដីធ្លី ដែលបានបង់សំរាប់គេហដ្ឋានកំពុងរស់នៅ
- ចំនួនដែលបានបង់ដោយភ្នាក់ងាររដ្ឋ ទៅឲ្យគ្រួសារមានសមាជិកដែលពិការវឌ្ឍនភាព និងកំពុងតែរស់នៅក្នុងផ្ទះ ដើម្បីរំលោះដំឡៃនៃសេវា និងប្រដាប់ប្រដាដែលត្រូវការ ដើម្បីរក្សាសមាជិកគ្រួសារដែលពិការវឌ្ឍនភាព ឲ្យនៅផ្ទះបាន

ការផាត់ចេញដែលរដ្ឋបាលសហព័ន្ធបានដាក់អាណត្តិ :

- ដំឡៃនៃចំណែកប្រាក់ ដែលបានផ្តល់ទៅឲ្យក្រុមគ្រួសារដែលមានសិទ្ធិទទួល ក្រោមក្រឹត្យហ្វ៊ូតស្តែម (Food Stamp Act) នៃឆ្នាំ 1977
- ការបង់ប្រាក់ ទៅឲ្យអ្នកស្ម័គ្រចិត្តធ្វើការ ក្រោមក្រឹត្យសេវានៃជនឧស្សាហ៍ស្ម័គ្រក្នុងគ្រួសារ (Domestic Volunteer Services) នៃឆ្នាំ 1973
- ការបង់ប្រាក់ បានទទួលក្រោមក្រឹត្យការសំរុះសំរួលបណ្តឹងជនជាតិដើមអាឡាស្កា (Alaska Native Claims Settlement Act)
- ប្រាក់ចំណូលបានមកពីដីវាយរងខ្លះនៃសហរដ្ឋ ដែលបានដំកល់ទុកសំរាប់កុលសម្ព័ន្ធឥណ្ឌានខ្លះ
- ការបង់ប្រាក់ ឬប្រាក់អនុញ្ញាត
បានបង់ឲ្យក្រោមកម្មវិធីរបស់ក្រសួង សុខភាព
និងសេវាមនុស្សសំរាប់អ្នកមានប្រាក់ចំណូលតិច និង
ជំនួយថាមពលផ្ទះ (Department of Health and Human Services' Low-Income Home Energy Assistance Program)
- ការបង់ប្រាក់ បានទទួលក្រោមកម្មវិធីដែលបានផ្តល់ថវិកាទាំងស្រុង ឬផ្នែកនៃក្រឹត្យសហប្រតិបត្តិការហ្វឹកហ្វឺនការងារ (Job Training Partnership Act)
- ប្រាក់ចំណូលបានមកចេញពីការផ្ទេរកម្មសិទ្ធិ ទៅឲ្យ Grand River Band ឥណ្ឌាននៅក្រុងអូត្តាវ៉ា
- ចំនួន $2000 ដំបូងនៃចំណែកនិមួយៗ បានទទួលមកពីការកាត់ក្តីថវិកាដែលបានសំរេចឲ្យ ដោយគណៈកម្មការបណ្តឹងជនជាតិឥណ្ឌាន (Indian Claims Commission) ឬសហរដ្ឋ ។ បណ្តឹងតុលាការ, ការប្រាក់នៃជនជាតិឥណ្ឌាននិមួយៗបានដំកល់ទុក ឬទឹកដីមានលក្ខខ័ណ្ឌ រួមទាំង $2000 ដំបូងក្នុងមួយឆ្នាំនៃប្រាក់ចំណូល ចេញមកពីថវិកាបានមកពី ការប្រាក់ដែលបានដំកល់ទុក ឬទឹកដីមានលក្ខខ័ណ្ឌបែបនោះ

- ចំនួននៃជំនួយថវិកាផ្តល់ឲ្យនិស្សិត ក្រោមមាត្រាទី IV នៃក្រឹត្យការអប់រំខ្ពង់ខ្ពស់ជាង (Higher Education Act) នៃឆ្នាំ 1965 រួមទាំងរង្វាន់នៅក្រោមកម្មវិធីធ្វើការ-សិក្សា រដ្ឋបាលសហព័ន្ធ ឬក្រោមការិយាល័យកិច្ចការឥណ្ឌាន (Bureau of Indian Affairs) កម្មវិធីជំនួយសិស្ស
- ការបើកប្រាក់ បានទទួលមកពីកម្មវិធីបានផ្តល់ថវិកា ក្រោមមាត្រាទី V នៃក្រឹត្យជនអាមេរិកាំងវ័យចាស់ (Older Americans Act) នៃឆ្នាំ 1985
- ការបើកប្រាក់ បានទទួលនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា 1989 ចេញពីភ្នាក់ងារការសំរុះសំរួលថវិកា Orange (Agent Orange Settlement Fund) ឬថវិកាផ្សេងទៀតដែលបានស្ថាបនា ដោយអនុលោមទៅតាមការសំរុះសំរួលក្នុង*ភ្នាក់ងារសាថ្មី (Re Agent)* ផលនៃភាពទទួលខុសត្រូវវិវាទ
- ការបើកប្រាក់ បានទទួលក្រោមក្រឹត្យការសំរុះសំរួលបណ្តឹងឥណ្ឌាន នៅរដ្ឋ Maine (Maine Indian Claims Settlement Act) នៃឆ្នាំ 1980
- ដំឡៃនៃថ្លៃថែទាំក្មេង ដែលបានផ្តល់ ឬបានរៀបចំ (ឬចំនួនអ្វីមួយដែលបានទទួលជាការបង់ប្រាក់សំរាប់ការថែទាំបែបនោះ ឬការចេញសងឲ្យវិញសំរាប់ដំឡៃការថែទាំបែបនោះដែលវ័ណ្ឌ) ក្រោមក្រឹត្យការថែទាំក្មេង និងផ្នែកប្រាក់សម្បទានវឌ្ឍនកម្ម (Child Care and Development Block Grant Act) នៃឆ្នាំ 1990
- ការបានប្រាក់មកវិញ អំពីឥណទានពន្ធដារលើប្រាក់ចំណូល (Earned income tax credit - EITC) នៅចំថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា 1991
- ការបើកប្រាក់ ដោយគណៈកម្មការបណ្តឹងជនជាតិឥណ្ឌាន (Indian Claims Commission) ទៅឲ្យកុលសម្ព័ន្ធបានចូលសម្ព័ន្ធ (Confederated Tribes) និងក្រុមសាសន៍ឥណ្ឌាន Yakima (Bands of Yakima Indian Nation) ឬដីបំរុងទុកសំរាប់កុល សម្ព័ន្ធ Apache នៅ Mescalero (Apache Tribe of Mescalero Reservation)
- ប្រាក់អនុញ្ញាត, ប្រាក់រកបាន និងការបើកប្រាក់ទៅឲ្យអ្នកចូលរួមក្នុង AmeriCorps ក្រោមក្រឹត្យសេវាជាតិនិងសហគមន៍ (National and Community Service Act) នៃឆ្នាំ 1990
- ប្រាក់អនុញ្ញាតអ្វីមួយដែលបានបង់ឲ្យក្រោមប្រការបញ្ញត្តិនៃ 38U.S.C. 1805 ទៅឲ្យក្មេងៗដែលវេទនាអំពីសព្បែកទ្រនង់ឆ្អឹងខ្នង ដែលជាកូនរបស់អតីតយុទ្ធជនសង្គ្រាមវៀតណាម
- ចំនួនអ្វីមួយនៃការចេញសងឲ្យជនរងគ្រោះឧក្រិដ្ឋកម្ម (ក្រោមក្រឹត្យជនរងគ្រោះឧក្រិដ្ឋកម្ម - Victims of Crime Act) ដែលបានទទួលតាមរយៈជំនួយជនរងគ្រោះឧក្រិដ្ឋកម្ម (ឬការបង់ប្រាក់ ឬការឲ្យប្រាក់មកវិញ នូវដំឡៃនៃជំនួយបែបនោះ) ដូចបានអនុម័តក្រោមក្រឹត្យជនរងគ្រោះឧក្រិដ្ឋកម្ម ពីព្រោះការប្រព្រឹត្តិបទឧក្រិដ្ឋប្រឆាំងនឹងអ្នកដាក់ពាក្យសុំ ក្រោមក្រឹត្យជនរងគ្រោះឧក្រិដ្ឋកម្ម
- ប្រាក់អនុញ្ញាត, ប្រាក់រកបាន និងការបើកប្រាក់ទៅឲ្យបុគ្គលដែលចូលរួម ក្រោមក្រឹត្យវិនិយោគកំឡាំងការងារ (Workforce Investment Act) នៃឆ្នាំ 1998
- អត្ថប្រយោជន៍ភាពពិការអ្វីមួយ ដែលលើកពេលដោយក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veterans Affairs) ដែលបានទទួលជាសរុបចំនួន ឬជាចំនួនប្រចាំខែនៅអនាគត ដោយអ្នកជួលផ្ទះ ដើម្បីប្រតិបត្តិតាមក្រឹត្យទីលំនៅនិងការស្តារសេដ្ឋកិច្ច (Housing and Economic Recovery Act - HERA) នៃឆ្នាំ 2008 ។

ការកាត់បន្ថយ ៖

- $480 សំរាប់មនុស្សក្នុងបន្ទុកនិមួយៗ រួមទាំងសិស្សរៀនពេញពេល ឬមនុស្សដែលពិការ
- $400 សំរាប់គ្រួសារនៃមនុស្សចាស់ជរា ឬគ្រួសារដែលពិការ
- ការចំណាយថ្លៃពេទ្យដែលមិនបានសងឲ្យវិញ នៃគ្រួសារមនុស្សចាស់ជរា ឬគ្រួសារដែលពិការ ដែលសរុបទាំងអស់ច្រើនជាង 3% នៃប្រាក់ចំណូលប្រចាំឆ្នាំ
- ថ្លៃជួលមនុស្សមកថែទាំដោយសមហេតុផល និងការចំណាយលើគ្រឿងជំនួយ ដែលមិនបានសងឲ្យវិញ សំរាប់សមាជិកគ្រួសារដែលពិការ ដើម្បីអនុញ្ញាតឲ្យសមាជិកគ្រួសារអាចទៅធ្វើការបាន ដែលសរុបទាំងអស់ច្រើនជាង 3% នៃប្រាក់ចំណូលប្រចាំឆ្នាំ
- បើគ្រួសារនៃមនុស្សចាស់ជរា មិនបានសងឲ្យវិញ សំរាប់ការចំណាយថ្លៃពេទ្យ និងការចំណាយជំនួយភាពពិការទាំងពីរមុខ ការចំណាយ 3% នៃប្រាក់ចំណូលរបស់គ្រួសារ គឺបានយកមកប្រើតែម្តងប៉ុណ្ណោះ
- ការចំណាយថ្លៃថែទាំក្មេងអ្វីដែលសមហេតុផល សំរាប់ក្មេងៗក្រោម អាយុ 13 ឆ្នាំ ដែលជាចាំបាច់ប្រយោជន៍ឲ្យសមាជិកគ្រួសារអាចធ្វើ ការងារបាន ឬដើម្បីបន្តការសិក្សារបស់គេទៀត ។

## សំភារៈជាសំអាង

បញ្ញត្តិ ៖

- សេចក្តីដំរូវទូទៅកម្មវិធី HUD (General HUD Program Requirements); 24 CFR ផ្នែកទី 5

សៀវភៅតម្រា ៖

- 4350.3, សេចក្តីដំរូវការរស់នៅ នៃកម្មវិធីទីលំនៅច្រើនគ្រួសារ បានឧបត្ថម្ភប្រាក់ (Occupancy Requirements of Subsidized Multifamily Housing Programs)

កំណត់សំគាល់ ៖

- សេចក្តីកំណត់ "ការផាត់ចេញរដ្ឋបាលសហព័ន្ធបានដាក់អាណត្តិ" (Federally Mandated Exclusions) ថ្ងៃទី 20 ខែមេសា 2001

សំរាប់ព័ត៌មានបន្ថែម

ស្វែងយល់ថែមទៀតអំពីកម្មវិធីរបស់ HUD នៅលើគេហទំព័រវ៉ិបសៃត៍របស់ HUD នៅ http://www.hud.gov